តើអ្នកដឹងទេ?
DID YOU KNOW?

ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# ការប្រឡងប្រជែងជ្រើសរើសមន្ត្រី និងអត្ថប្រយោជន៍ការងារ

# សិស្សមន្ត្រីក្រមការ ជំនាន់ទី១១

ឲ្យចូលរៀននៅសាលាភូមិន្ទរដ្ឋបាល

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

## វិញ្ញាសាសរសេរលើកទី១

សំណួរពហុចម្លើយពាក់ព័ន្ធនឹងវប្បធម៌ទូទៅ ច្បាប់ រដ្ឋបាល នយោបាយ អាស៊ាន សេដ្ឋកិច្ច និងហិរញ្ញវត្ថុ «រយៈពេល ១ម៉ោង៣០នាទី» ១០០ពិន្ទុ មេគុណ ១

## វិញ្ញាសាសរសេរលើកទី២

១

អធិប្បាយពាក់ព័ន្ធនឹងចំណេះដឹងទូទៅផ្នែកច្បាប់ រដ្ឋបាល សេដ្ឋកិច្ច វប្បធម៌ទូទៅ និងសំណួរខ្លីពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ភូមិសាស្ត្រ សីលធម៌ ពលរដ្ឋវិទ្យា អរិយធម៌ និងវប្បធម៌ «រយៈពេល ៣ម៉ោង០០នាទី» ១០០ពិន្ទុ មេគុណ ២

២

ភាសាអង់គ្លេស ឬភាសាបារាំង «រយៈពេល ១ម៉ោង០០នាទី» ១០០ពិន្ទុ មេគុណ ១

បញ្ជាក់៖ មានតែបេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរលើកទី២ តែប៉ុណ្ណោះ ដែលនឹងត្រូវអនុញ្ញាតឱ្យចូលរួមប្រឡងវិញ្ញាសួរផ្ទាល់មាត់។

**គុណធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព**

# អត្ថប្រយោជន៍ការងារ

១

ក្នុងរយៈពេលបណ្ដុះបណ្ដាល សិស្សត្រូវបានផ្ដល់ប្រាក់ឧបត្ថម្ភប្រចាំខែ ផ្អែកតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

២

សិស្សមន្ត្រីក្រមការដែលទទួលការបណ្ដុះបណ្ដាលប្រកបដោយជោគជ័យ នឹងទទួលបានសញ្ញាបត្រមន្ត្រីក្រមការ។

៣

សិស្សមន្ត្រីក្រមការដែលជ្រើសរើសពីក្នុងចំណោមនិស្សិត ហើយទទួលការបណ្ដុះបណ្ដាលប្រកបដោយជោគជ័យតាមកម្មវិធីសិក្សារយៈពេល ១២ខែ ត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ខ** និងផ្ដល់២ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលសិស្សមន្ត្រីត្រូវបានចាត់បញ្ចូល ចំពោះអ្នកមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិបូក២ឆ្នាំនៃការសិក្សាបន្ថែមនៅឧត្ដមសិក្សា និងផ្ដល់៣ថ្នាក់បន្ថែមចាប់ពីថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលសិស្សមន្ត្រីត្រូវបានចាត់បញ្ចូល ចំពោះអ្នកមានបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ។

៤

សិស្សមន្ត្រីក្រមការដែលជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ហើយទទួលការបណ្ដុះបណ្ដាលប្រកបដោយជោគជ័យតាមកម្មវិធីសិក្សារយៈពេលយ៉ាងតិច ១២ខែត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ខ** ដោយផ្ដល់ថ្នាក់ដូចលក្ខខណ្ឌដែលមានកំណត់ក្នុងចំណុចទី៣ខាងលើ ឬត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការប្រភេទ **ខ** និងផ្ដល់ ២ថ្នាក់បន្ថែមលើថ្នាក់ដែលមានស្រាប់របស់សាមីជន ដោយត្រូវរៀបចំផ្អែកលើករណីដែលផ្ដល់ប្រយោជន៍ដល់សិស្សមន្ត្រី។

៥

សិស្សមន្ត្រីក្រមការដែលបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការរួចហើយ និងទទួលប្រាក់បំណាច់មុខងារស្មើនឹងអនុប្រធានការិយាល័យ។

**គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព**